ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ធំ ប្រធានការិយាល័យអប់រំ យុវជន និង កីឡា ស្រុក បារាយណ៍ នាយកសាលាបឋមសិក្សា ប៊ុន រ៉ានី ហ៊ុន សែន ស្វាយជីអោក មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សាអន

★★★

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៨

**ប្រកាសលេខ ៧៣៥ អយក.ប្រ.ក**

**ស្តីពីការផ្តល់សាលាឧបសម្ព័ន្ធ " ព្រះធន្លេ " មកជា**

**សាលាបឋមសិក្សា ពេញលក្ខណៈ**

****

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំរយៈពេល ១២ ឆ្នាំ

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៩៩៧/១៥៧ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានពិនិត្យលិខិតស្នើសុំរបស់គណៈកម្មការទ្រទ្រង់សាលាឧបសម្ព័ន្ធព្រះធន្លេ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៧ និងចំណារឯកភាពរបស់ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តស្វាយរៀង លេខ ១០០២ ចប.អយក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៧

-តាមសេចក្តីឯកភាពរបស់នាយកដ្ឋានបឋម និង អគ្គាធិការសិក្សា

**សំរេច**

ប្រការ ១ : ផ្តាច់សាលាឧបសម្ព័ន្ធ ព្រះទន្លេ ពីសាលាបឋមសិក្សា សាមគ្គី ដែលមានទីតាំងស្ថិតនៅ ឃុំសង្ឃ័រ ស្រុក ស្វាយទាប ខេត្តស្វាយរៀង មកជាសាលាបឋមសិក្សា ពេញលក្ខណៈ វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៧-៩៨ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា ព្រះទន្លេ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្តស្វាយរៀង ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកស្វាយទាប នាយកសាលាបឋមសិក្សា " ព្រះទន្លេ "មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សាហន

★ ★ ★

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៨

## ប្រកាសលេខ ៧៣៦ អយក.ប្រ.ក

## ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ " ព្រៃរំដួល " មកជា សាលាបឋមសិក្សា ពេញលក្ខណៈ

****

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ